**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ស្ថិតក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជនមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១- ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | ប្រធាន |
| ២- រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |

| | |
|---|---|
| ៤- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធាន |
| ៦- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦- អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៧- អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា២._**

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជនមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាប្រឈម ឬសំណូមពររបស់វិស័យឯកជន លើទិដ្ឋភាពច្បាប់ បច្ចេកទេស ឬផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចចម្រុះ ត្រូវដោះស្រាយដោយអន្តរក្រសួងនិង/ឬអន្តរស្ថាប័ន និងដែលលើសពីដែនសមត្ថកិច្ច ឬលទ្ធភាពសម្រេចរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងយន្តការដទៃទៀត រួមទាំងយន្តការក្រុមការងារជំរុញការវិនិយោគក្នុង ខេត្តព្រះសីហនុ
- ធ្វើការពិនិត្យ តាមដាន វាយតម្លៃ និងរាយការណ៍ជូននាយករដ្ឋមន្ត្រីចំពោះរាល់បញ្ហាប្រឈម និងសំណូមពរដើម្បីជំរុញការដោះស្រាយ និង/ឬលើកកម្ពស់បរិយាកាសវិនិយោគ និងធុរកិច្ច
- ដោះស្រាយបញ្ហាប្រឈម ឬសំណូមពររបស់វិស័យឯកជន តាមករណីនីមួយៗ តាមការបញ្ជាផ្ទាល់ ពីនាយករដ្ឋមន្ត្រី
- បំពេញភារកិច្ចដទៃទៀត តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**មាត្រា៣.-**

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានធនធានហិរញ្ញវត្ថុ ក្រោមការគ្រប់គ្រងរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងមានសិទ្ធិប្រើត្រារបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី សម្រាប់បំពេញភារកិច្ច។

**មាត្រា៤.-**

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬមានសិទ្ធិសម្រេចក្នុងនាមប្រធានក្រសួង ស្ថាប័ន តាមការចាំបាច់ ដើម្បីចូលរួមបំពេញភារកិច្ចរបស់គណៈកម្មាធិការ។

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានសិទ្ធិអញ្ជើញស្ថាប័នស្រាវជ្រាវ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអ្នកជំនាញការ ដើម្បីផ្តល់ព័ត៌មាននិងយោបល់នានា ពាក់ព័ន្ធនឹងការបំពេញ ភារកិច្ចរបស់ខ្លួន។

**មាត្រា៥.-**

ប្រធានគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ទទួលខុសត្រូវរួមក្នុងការដឹកនាំគណៈកម្មាធិការ និងដឹកនាំកិច្ចប្រជុំ ។ ប្រធានអាចចាត់តាំងអនុប្រធានឬសមាជិកគណៈកម្មាធិការដឹកនាំការងារជំនួស ក្នុងករណីចាំបាច់ឬប្រធានអវត្តមាន។

**មាត្រា៦.-**

គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន មានលេខាធិការដ្ឋានមួយជាសេនាធិការ។

លេខាធិការដ្ឋាននេះមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១- នាយករងខុទ្ទកាល័យនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- តំណាងគណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធាន |
| ៤- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៦- តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៩- តំណាងក្រសួងទេសចរណ៍ | សមាជិក។ |

**មាត្រា៧.-**

លេខាធិការដ្ឋានគណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន ដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាល និងមានការិយាល័យនៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម ៖

- ផ្ដល់សេវាគាំទ្រ និងបំពេញការងារ សម្រាប់ប្រក្រតីភាពនៃកិច្ចដំណើរការប្រចាំថ្ងៃ របស់គណៈកម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន
- ពិនិត្យ វិភាគ និងលើកយោបល់ជូនគណៈកម្មាធិការពិនិត្យសម្រេច ព្រមទាំងសិក្សានិងប្រមូលធាតុចូលសម្រាប់គណៈកម្មាធិការ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ច ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញភារកិច្ចដទៃទៀតតាមការសម្រេចរបស់ប្រធានគណៈកម្មាធិការ។

**មាត្រា៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ [illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែសីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ